**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

៣៣ ❖ ៤៩

**ក្រសួងអប់រំ យុវជន និង កីឡា**

**លេខ :៤០៧ អយក.ប្រក**

## ប្រកាស

ស្តីពីការផ្តាច់សាលាឧបសម្ព័ន្ធ **ពោធិអង្គ**

មកជាសាលាបឋមសិក្សា ពេញលក្ខណៈ

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស . រកត - ១១៩៨ - ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស-រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ២១អនក្រ.បក ចុះថ្ងៃទី២៣ ខែមិនា ឆ្នាំ ៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានពិនិត្យលិខិតលេខ ១១២៤ អយក.បម ចុះថ្ងៃទី ២៣ ខែ ០១ ឆ្នាំ ២០០២ របស់មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត តាកែវ
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានបឋម និង មត្តេយ្យសិក្សា

## <u>សំរេច</u>

**ប្រការ១** : ផ្តាច់សាលាឧបសម្ព័ន្ធ **ពោធិអង្គ** ចេញពីសាលាបឋមសិក្សា **អ៊ីនួនអេត្រយឹង** ដែលមានទីតាំងស្ថិតនៅភូមិ **រាមអណ្តើក** ឃុំ**រាមអណ្តើក** ស្រុក **គីរីវង្ស** ខេត្ត **តាកែវ**មកជាសាលាបឋមសិក្សា ពេញលក្ខណៈវិញចាប់ពីឆ្នាំសិក្សា ២០០១-២០០២ នេះតទៅ ។

**ប្រការ២** : សាលាបឋមសិក្សា **ពោធិអង្គ** ត្រូវដឹកនាំដោយនាយកមួយរូប និង នាយករង តាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗ ស្របតាមបទដ្ឋាន ប្រើប្រាស់ក្របខ័ណ្ឌ សំរាប់សាលាបឋមសិក្សា ។

**ប្រការ៣** : នាយក នាយករង មានសិទ្ធិទទួលប្រាក់បំនាច់ភារកិច្ច តាមគោលការណ៍កំនត់របស់រដ្ឋ ។

**ប្រការ៤** : បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ៥** : នាយកដ្ឋានរដ្ឋបាល នាយកដ្ឋានបុគ្គលិក នាយកដ្ឋានហិរញ្ញវត្ថុ នាយកដ្ឋានបឋម និង មត្តេយ្យសិក្សា នៃក្រសួងអប់រំ យុវជន និង កីឡា មន្ទីរអប់រំ យុវជន និង កីឡា ខេត្ត **តាកែវ** ការិយាល័យអប់រំ យុវជន និង កីឡា ស្រុក គីរីវង្ស នាយកសាលាបឋមសិក្សា **ពោធិអង្គ** នាយកសាលាបឋមសិក្សា **អ៊ីនួនអេត្រយឹង** មានភារកិច្ច អនុវត្តប្រកាសនេះ ។

ភ្នំពេញ ,ថ្ងៃទី ២៨ ខែឧសភា ឆ្នាំ ២០០២

ជ-រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

រដ្ឋលេខាធិការ

អ៊ឹម សេធី

**<u>កន្លែងទទួល</u>** :

- ទីស្តីការគណៈរដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងផែនការ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- សាលាខេត្ត តាកែវ

" <u>ដើម្បីជូនជ្រាបជាពត៌មាន</u> "

- ដូចប្រការ ៥
- កាលប្បវត្តិ- ឯកសារ នា -ប.ម